# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី**

## កិច្ចព្រមព្រៀង

**រវាង**

## ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី ជាមួយតំណាងកម្មករ និងសហជីព ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃ ខែ ឧសភា ថ្ងៃទី ៤ វេលាម៉ោង២ និង ០០នាទី ថ្ងៃត្រង់នៅការិយាល័យក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូអិលធីឌី មានកិច្ចប្រជុំពិភាក្សា រវាងតំណាងក្រុមហ៊ុន ប្រតិភូបុគ្គលិក និងថ្នាក់ដឹកនាំសហជីព សម្លេងយុវជនខ្មែរ ប្រចាំរោងចក្រ។ ក្រោយពីបានប្រជុំពិភាក្សា ភាគីទាំងពីរបានយល់ព្រមព្រៀងគ្នាដូចខាងក្រោមៈ

១-ភាគីទាំងពីរយល់ព្រមព្យួរការងាររយៈពេលពីរខែចំពោះកម្មករនិយោជិតមួយចំនួន ៤០០ នាក់ មានផ្នែកដេរ ផ្នែកវេចខ្ចប់ ផ្នែកពិនិត្យគុណភាព ផ្នែកជាងម៉ាស៊ីន ផ្នែកតុកាត់ ដោយគិតចាប់ ពីថ្ងៃទី១៨ ខែ ឧសភា ឆ្នាំ ២០២០ រហូតដល់ ថ្ងៃទី ១៧ ខែមិថុនាឆ្នាំ២០២០ ដោយសារអ្នកបញ្ជាទិញផ្អាកការបញ្ជាទិញព្រោះប្រទេសទាំងនោះរងផលប៉ះពាល់ពីជម្ងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរ ខូវីដ១៩ (COVID19)។

២-ភាគីកម្មករនិយោកជិតយល់ព្រមទទួលប្រាក់ឧបត្ថម្ភ ៣០ដុល្លារអាមេរិក ពីភាគីនិយោជក និង ៤០ ដុល្លារអាមេរិកដែរជាប្រាក់ឧបត្ថម្ភពិសេសរបស់រាជរដ្ឋាភិបាលដូច្នេះជាសរុបកម្មករនិយោជិតម្នាក់ទទួលបាន៧០ ដុល្លារអាមេរិកក្នុង១ ខែសំរាប់រយៈពេលព្យួរការងារនេះ។

៣-ក្រុមហ៊ុននិងបើកជូនប្រាក់ឧបត្ថម្ភ៣០ ដុល្លារអាមរិកនេះជូនកម្មករនិយោជិត១ខែម្តង។

៤-បងប្អូនត្រូវត្រលប់ចូលមកធ្វើការវិញនាថ្ងៃទី ១៨ ខែ មិថុនា ឆ្នាំ ២០២០ ក្នុងករណីបងប្អូន កម្មករមិនបានចូលធ្វើការតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តន៏តាមច្បាប់ស្តីពីការងារនិងបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន។

កិច្ចព្រមព្រៀងនេះ ចាប់អនុវត្តន៏និងមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១៣កើត ខែ ពិសាខ ឆ្នាំជូត ទោស័ក២៥៦៤

កំពង់ស្ពឺ ថ្ងៃទី ០៤ ខែ ឧសភា ឆ្នាំ ២០២០

**ស្នាមមេដៃតំណាងកម្មករនិយោជិត**

១- ....................

២- ....................

៣- Keov Sineth

៤- Yong Choeun

៥- ....................

៦- ....................

៧- ....................

**តំណាងក្រុមហ៊ុន**

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន សេរី (ខេមបូឌា) ហ្គាម៉ិន ខូ អិលធីឌី CERIE (CAMBODIA) GARMENT Co., Ltd. KINGDOM OF CAMBODIA